**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ខេត្តព្រះវិហារ**

**រដ្ឋបាលស្រុកគូលែន**

លេខៈ ០១៦ ដ.ក

អង្គភាពប្រឆាំងអំពើពុករលួយ
ចូល
លេខ ១២០៩ / ២០២៦
ថ្ងៃទី១៧.០៧.២៦ ម៉ោង០៩:៥០

# ដីកា

## ស្តីពី

## ការកំណត់កម្រៃសេវារដ្ឋបាលស្រុក

## ក្រុមប្រឹក្សាស្រុកគូលែន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទីភារកិច្ច និងទំនាក់ទំនងរបស់ក្រុមប្រឹក្សាគណៈអភិបាលខេត្ត ក្រុមប្រឹក្សាគណៈអភិបាលក្រុង និងក្រុមប្រឹក្សាគណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ ២៨៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីនីតិវិធីសម្រាប់ការរៀបចំ ការកែប្រែ និងការលុបចោលដីការបស់ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសអន្តរក្រសួងលេខ ៣៨៥៦ ប្រ.ក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសអន្តរក្រសួងលេខ ៣៤៣ សហវ.ប្រក.អទច ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៦ របស់ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវារដ្ឋបាលក្រុង ស្រុក ខណ្ឌ
- យោងកិច្ចប្រជុំសាមញ្ញលើកទី២៥ របស់ក្រុមប្រឹក្សាស្រុកគូលែន អាណត្តិទី៤ នាថ្ងៃអង្គារ ៩កើត ខែបឋមសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស២៥៧០ ត្រូវនឹងថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២៦។

## សម្រេច

### ជំពូកទី១

### បទបញ្ញត្តិទូទៅ

**ប្រការ១.-**

ដីកានេះមានគោលបំណងធានាឱ្យការកំណត់តម្លៃសេវារដ្ឋបាល នៅរដ្ឋបាលស្រុកគូលែន មានលក្ខណៈសមស្របតាមស្ថានភាព និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

**ប្រការ២.-**

ដីកានេះមានគោលដៅកំណត់តម្លៃសេវារដ្ឋបាលជាក់ស្តែង ចំពោះតម្លៃសេវាអតិបរមាដែលបានកំណត់ដោយប្រកាសអន្តរក្រសួងលេខ ៣៤៣ សហវ.ប្រក.អទច ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៦ របស់ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវារដ្ឋបាលក្រុង ស្រុក ខណ្ឌ។

**ប្រការ៣.-**

ដីកានេះមានវិសាលភាពអនុវត្តនៅក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលស្រុកគូលែន។

### ជំពូកទី២

### តម្លៃសេវារដ្ឋបាល

**ប្រការ៤.-**

តម្លៃសេវារដ្ឋបាលជាក់ស្តែងនៃតម្លៃសេវាអតិបរមារបស់រដ្ឋបាលស្រុកគូលែន ត្រូវបានកំណត់ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធដែលភ្ជាប់នឹងដីកានេះ។

ចំពោះតម្លៃសេវារដ្ឋបាលជាក់លាក់នៃប្រភេទសេវាផ្សេងៗទៀត ត្រូវអនុវត្តតាមតម្លៃសេវាដូចមានកំណត់នៅក្នុងកម្រងតារាងសេវារដ្ឋបាលដូចមានចែងក្នុងតារាងឧបសម្ព័ន្ធ ដែលបានភ្ជាប់នឹងប្រកាសអន្តរក្រសួងលេខ ៣៤៣ សហវ.ប្រក.អទច ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៦ របស់ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីការផ្តល់សេវារដ្ឋបាលក្រុង ស្រុក ខណ្ឌ។

**ប្រការ៥.-**

ចំពោះប្រជាពលរដ្ឋដែល មានប័ណ្ណក្រីក្រ ដែលបញ្ជាក់ទទួលស្គាល់ដោយរដ្ឋបាលឃុំ ត្រូវកំណត់ដូចខាងក្រោម៖

- អ្នកមានប័ណ្ណក្រីក្រប្រភេទ១ និងប្រភេទ២ និងប័ណ្ណហានិភ័យ មិនកំណត់យកកម្រៃសេវា
    - (ទាក់ទងនិងការងារនីត្យានុកូលកម្ម ដែលបានកំណត់ក្នុងតារាងឧបសម្ព័ន្ធនៃដីកានេះ)
    - អ្នកមានប័ណ្ណក្រីក្រប្រភេទ១ និងប្រភេទ២ ត្រូវកំណត់មិនយកកម្រៃសេវាស្មើនឹង ១00% ដែលបានកំណត់ក្នុងតារាងឧបសម្ព័ន្ធនៃដីកានេះ

**ប្រការ៦.-**

កំណត់យកសេវាផ្ទេរកម្មសិទ្ធដីធ្លីមិនទាន់ចុះបញ្ជីដូចខាងក្រោម៖

១.ការផ្ទេរសិទ្ធិកាន់កាប់អចលនវត្ថុមិនទាន់ចុះបញ្ជីចំពោះដីផលិតកម្ម កសិក

-ទំហំលើសពី ១០.០០០ម$^{២}$(គិតក្នុងមួយម៉ែត្រការេ) ១៥៛

២.ការផ្ទេរសិទ្ធិកាន់កាប់អចលនវត្ថុមិនទាន់ចុះបញ្ជីចំពោះដីលំនៅឋាន ឬដីសាងសង់
-ទំហំលើសពី ១០.០០០ម²(គិតក្នុងមួយម៉ែត្រការេ) ៣០៛

- (ទាក់ទងនិងវិស័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ដែលបានកំណត់ក្នុងតារាងឧបសម្ព័ន្ធនៃដីកានេះ)

**ជំពូកទី៣**

**អវសានប្បញ្ញត្តិ**

**ប្រការ៧.-**

រាល់បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីដីកានេះត្រូវទុកជានិរាករណ៍។

**ប្រការ៨.-**

គណៈអភិបាល នាយករដ្ឋបាល និងអង្គភាពនានានៃរដ្ឋបាលស្រុកគូលែន ត្រូវទទួលបន្ទុកអនុវត្តដីកានេះ ចាប់ពីថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៦។

ថ្ងៃអង្គារ ៩កើត ខែបឋមសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស២៥៧០
ស្រុកគូលែនថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៦
ជ.គ្រុមប្រឹក្សាស្រុក
ប្រធាន

**កន្លែងទទួល**
- *ក្រសួងមហាផ្ទៃ*
- *ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
- *អង្គភាពប្រឆាំងអំពើពុករលួយ*
- *គ្រប់រដ្ឋបាលឃុំក្នុងដែនសមត្ថកិច្ចស្រុក*
- *គ្រប់មន្ទីរ/ការិយាល័យ*
- *ដូចប្រការ៨*
- *ឯកសារកាលប្បវត្តិ*

# តារាងឧបសម្ព័ន្ធ

ភ្ជាប់នឹងដីការដ្ឋបាលស្រុកគូលែន ខេត្តព្រះវិហារ លេខ:០១៦ ដ.ក ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៦ ស្ដីពីការកំណត់សេវារដ្ឋបាលស្រុក របស់រដ្ឋបាលស្រុកគូលែន ខេត្តព្រះវិហារ។

| ល.រ | លេខរៀងសេវា | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលអតិបរិមា (ថ្ងៃធ្វើការ) | សុពលភាព | ចំនួន |
|---|---|---|---|---|---|---|
| | | | តម្លៃជាកំណត់ | | | |
| **១-ការងារនីត្យានុកូលកម្ម** | | | | | | |
| ការបញ្ជាក់ភាពត្រឹមត្រូវតាមច្បាប់ដើមលើឯកសារ(គិតក្នុងមួយសន្លឹក) | | | | | | |
| ១ | ១ | សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ | មិនគិតថ្លៃ | ៣ថ្ងៃ | អចិន្ត្រៃយ៍ | សន្លឹក |
| ២ | ២ | សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ | មិនគិតថ្លៃ | ៣ថ្ងៃ | អចិន្ត្រៃយ៍ | សន្លឹក |
| ៣ | ៣ | សញ្ញាបត្រមធ្យមសិក្សាកម្រិត២(បំពេញវិជ្ជា) | មិនគិតថ្លៃ | ៣ថ្ងៃ | អចិន្ត្រៃយ៍ | សន្លឹក |
| ៤ | ៦ | សញ្ញាបត្របរិញ្ញាបត្ររង | មិនគិតថ្លៃ | ៣ថ្ងៃ | អចិន្ត្រៃយ៍ | សន្លឹក |
| ៥ | ៧ | សញ្ញាបត្របរិញ្ញាបត្រ | មិនគិតថ្លៃ | ៣ថ្ងៃ | អចិន្ត្រៃយ៍ | សន្លឹក |
| ៦ | ៩ | វិញ្ញាបនបត្របណ្ដោះអាសន្នមធ្យមសិក្សាគ្រប់កម្រិត | | | | |
| ៧ | ១០ | វិញ្ញាបនបត្របណ្ដោះអាសន្នថ្នាក់បរិញ្ញាបត្ររង | មិនគិតថ្លៃ | ៣ថ្ងៃ | អចិន្ត្រៃយ៍ | សន្លឹក |
| ៨ | ១១ | វិញ្ញាបនបត្របណ្ដោះអាសន្នថ្នាក់បរិញ្ញាបត្រ | មិនគិតថ្លៃ | ៣ថ្ងៃ | អចិន្ត្រៃយ៍ | សន្លឹក |
| ៩ | ១២ | វិញ្ញាបនបត្រ ឬលិខិតបញ្ជាក់ការសិក្សាគ្រប់កម្រិត | មិនគិតថ្លៃ | ៣ថ្ងៃ | អចិន្ត្រៃយ៍ | សន្លឹក |
| ១០ | ១៣ | វិញ្ញាបនបត្រ | មិនគិតថ្លៃ | ៣ថ្ងៃ | អចិន្ត្រៃយ៍ | សន្លឹក |
| ១១ | ១៤ | ព្រឹត្តិបត្រពិន្ទុ | មិនគិតថ្លៃ | ៣ថ្ងៃ | អចិន្ត្រៃយ៍ | សន្លឹក |
| ១២ | ១៥ | ព្រឹត្តិបត្រលទ្ធផលប្រលងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ | មិនគិតថ្លៃ | ៣ថ្ងៃ | អចិន្ត្រៃយ៍ | សន្លឹក |
| ១៣ | ១៦ | លិខិតបញ្ជាក់ការសិក្សា | មិនគិតថ្លៃ | ៣ថ្ងៃ | អចិន្ត្រៃយ៍ | សន្លឹក |
| ១៤ | ១៧ | លិខិតបញ្ជាក់លទ្ធផលនៃការប្រលងសញ្ញាបត្រមធ្យមសិក្សាកម្រិត១ | មិនគិតថ្លៃ | ៣ថ្ងៃ | អចិន្ត្រៃយ៍ | សន្លឹក |

| | | | | | | |
|---|---|---|---|---|---|---|
| ១៥ | ១៨ | ពាក្យសុំបញ្ជាក់សញ្ញាបត្រមធ្យមសិក្សាកម្រិត២ ចំណេះដឹងទូទៅ | មិនគិតថ្លៃ | ៣ថ្ងៃ | អចិន្ត្រៃយ៍ | សន្លឹក |
| ១៦ | ១៩ | អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ | មិនគិតថ្លៃ | ៣ថ្ងៃ | អចិន្ត្រៃយ៍ | សន្លឹក |
| ១៧ | ២០ | សៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារ | មិនគិតថ្លៃ | ៣ថ្ងៃ | អចិន្ត្រៃយ៍ | សន្លឹក |
| **២-វិស័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល** | | | | | | |
| ការផ្ទេរសិទ្ធិកាន់កាប់អចលនវត្ថុមិនទាន់ចុះបញ្ជីចំពោះដីផលិតកម្ម កសិកម្ម | | | | | | |
| ១៨ | ២៥៩ | ទំហំលើសពី ១០.០០០ម$^2$( គិតក្នុងមួយម៉ែត្រការេ ) | ១៥ | ១៥ថ្ងៃ | | |
| ការផ្ទេរសិទ្ធិកាន់កាប់អចលនវត្ថុមិនទាន់ចុះបញ្ជីចំពោះដីលំនៅឋាន ឬដីសាងសង់ | | | | | | |
| ១៩ | ២៦២ | ទំហំលើសពី ១០.០០០ម$^2$( គិតក្នុងមួយម៉ែត្រការេ ) | ៣០ | ១៥ថ្ងៃ | | |

ថ្ងៃអង្គារ ៩កើត ខែបឋមសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស២៥៧០

ស្រុកគូលែនថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៦

**ច.ក្រុមប្រឹក្សាស្រុក**

**ប្រធាន**

**ជុំ ឆវី**